THE EDUCATION STATE

EARLY CHILDHOOD

# ដំណាក់កាលត្រៀម៖ ការចាប់ផ្តើម ចូលរៀនដោយមានទំនុកចិត្ត

## ប័ណ្ណព័ត៌មានសម្រាប់គ្រួសារ

**ខណ:ពេលដែលលោកអ្នក និងកូនរបស់លោកអ្នករៀបចំសម្រួលខ្លួនក្នុងឆ្នាំនេះ ការចាប់ផ្តើមចូលរៀនហាក់បីក៏ដូចជានៅរយ:ពេលយូរទៀត។ ការចាប់ផ្តើមចូល រៀនអាចជាការលំបាកផង និងរំភើបផង ហើយប័ណ្ណព័ត៌មាននេះផ្តល់ជូន ព័ត៌មានខ្លះៗ អំពីរបៀបដែលកម្មវិធីអប់រំកុមារវ័យក្មេងរបស់កូនលោកអ្នកនឹងជួយដល់លោកអ្នក និងដំណាក់កាលត្រៀមចូលសាលារៀនរបស់កូនលោកអ្នក ខណ:ពេលដែលឆ្នាំសិក្សាបិតចូលមកដល់។**

កូនរបស់លោកអ្នកបានឆ្លងកាត់ដំណាក់កាលផ្សេងៗមានតូច និងធំនៅក្នុងឆាក ជីវិត។ របៀបដែលកូនរបស់លោកអ្នកមានប្រតិកម្មទៅនឹងបរិស្ថានថ្មី/មិនសូវស្គាល់ (ឧទាហរណ៍ នៅពេលលោកអ្នកទៅលំហែរសម្រាក ចាប់ផ្តើមចូលកន្លែងថែទាំកុមារ ឬសាលាមត្តេយ្យ ចូលរួមទិវាកុមារ ឬ ផ្លាស់ប្តូរពីសកម្មភាព មួយ ឬទម្លាប់មួយ ទៅមួយទៀតក្តី) ទាំងនេះផ្តល់រូបភាពទូទៅមួយអំពីរបៀប ដែលកូនរបស់លោកអ្នកមានប្រតិកម្មទៅនឹងស្ថានភាពថ្មីៗ និងថាតើលោកអ្នក នឹងផ្តល់របៀបគាំទ្រយ៉ាងណាដល់ពួកគេឱ្យបានល្អបំផុត។

## ហេតុអ្វីបានជា ការចាប់ផ្តើមចូលរៀនដោយមានទំនុកចិត្ត មានសារ:សំខាន់?

ការចាប់ផ្តើមចូលរៀនដោយមានទំនុកចិត្ត នាំឱ្យមានលទ្ធផលរៀនសូត្រ និងសុខុមាលភាពល្អប្រសើរសម្រាប់កូនរបស់លោកអ្នក ទាំងអំឡុងពេលត្រៀម និងបន្ទាប់ពីនេះ។ វាជួយគាំទ្រដល់និរន្តរភាពនៃការរៀនសូត្រ និងការរីកចម្រើន របស់កូនលោកអ្នក និងគាំទ្រដល់ពួកគេឱ្យមានអារម្មណ៍ ថាមានសុវត្ថិភាព មានទំនុកចិត្ត និងភ្ជាប់ទំនាក់ទំនងជាមួយមនុស្សថ្មីៗ និងទីកន្លែងថ្មីៗ។

## ការចុះឈ្មោះកូនរបស់លោកអ្នកចូលរៀន

សាលាបឋមសិក្សាភាគច្រើន ចាប់ផ្តើមការចុះឈ្មោះនៅខែឧសភា មួយឆ្នាំមុន ពេលកុមារចាប់ផ្តើមចូលរៀន។ ពេលលោកអ្នកចុះឈ្មោះកូនចូលរៀន លោកអ្នក អាចបង្កើនឱកាសខ្លួនឯងដើម្បីចាប់ផ្តើមស្គាល់សាលា តាមរយ:ដំណាក់កាល ត្រៀមនេះ កម្មវិធី និងសកម្មភាពសាលា។ ដំណាក់កាលត្រៀមដ៏ប្រសិទ្ធភាព បំផុតគឺចាប់ផ្តើម ពេលមុនដំណាច់ឆ្នាំ និងរយ:ពីរ បីថ្ងៃមុនដំបូង ពេលបន្ទាប់ ពីចូលរៀនហើយ។

## កម្មវិធីសិក្សារបស់ដំណាក់កាលត្រៀម និងសកម្មភាពនានា

ការចូលរួមក្នុងកម្មវិធីដំណាក់កាលត្រៀម និងសកម្មភាពនានា នឹងជួយលោក អ្នក និងកូនរបស់លោកអ្នកទទួលបានការយល់ដឹងកាន់តែច្បាស់អំពីលក្ខណ: សាលា និងបង្កើតចំណងមិត្តភាពជាមួយកុមារ និងក្រុមគ្រួសារផ្សេងទៀត មុនដែលនឹងចូលរៀនសាលា។

## របាយការណ៍អំពីការរៀនសូត្រ និងការរីកចម្រើននៅដំណាក់កាល ត្រៀម

គ្រូអប់រំកុមារវ័យក្មេងរបស់កូនលោកអ្នក នឹងសរសេរ *Transition Learning and Development Statement* (របាយការណ៍ស្តីអំពីការសិក្សាត្រៀម) មួយ។ របាយការណ៍ស្តីអំពីការសិក្សាត្រៀមនេះ សង្ខេបពីចំណង់ចំណូលចិត្ត ជំនាញ និងសមត្ថភាពរបស់កូនលោកអ្នក។ វាក៏នឹងកំណត់វិធីសាស្ត្រនីមួយៗ និងយុទ្ធសាស្ត្របង្រៀន ដើម្បីឱ្យសាលា និងគ្រូថ្នាក់ត្រៀមរបស់កូនលោកអ្នក អាចចាប់ផ្តើមស្គាល់កូនរបស់លោកអ្នកបានឆាប់រហ័ស និងរៀបចំគម្រោងកម្ម វិធីសិក្សា និងបង្រៀនឱ្យសមស្រប។

ប្រសិនបើលោកអ្នកមានគម្រោងបញ្ជូនកូនរបស់លោកអ្នកទៅ សេវាថែទាំក្រៅ ម៉ោងសាលា (OSHC) របាយការណ៍ស្តីអំពីការសិក្សាត្រៀម នឹងអាចគេចែក រំលែកជាមួយសេវា OSHC ផងដែរ។ របាយការណ៍ស្តីអំពីការសិក្សាត្រៀម កាត់អាចជួយអ្នកអប់រំ OSHC រៀបចំផែនការសម្រាប់ចំណង់ចំណូលចិត្តរបស់ កូនលោកអ្នក និងគាំទ្រដល់និរន្តភាពរវាងការអប់រំកុមារវ័យក្មេង សាលា និង OSHC។

របាយការណ៍ស្តីអំពីការសិក្សាត្រៀមនេះ អាចជួយលោកអ្នកស្វែងយល់ គាំទ្រ ប្រាស្រ័យទាក់ទងអំពី និងគាំទ្រដល់ការរៀ នសូត្ររបស់កូនលោកអ្នក ខណ: ពេលដែលពួកគេឆ្លងកាត់ដំណាក់កាលត្រៀមចូលរៀន។ លោកអ្នកនឹងបាន ទទួលសេចក្តីចម្លង នៃរបាយការណ៍ស្តីអំពីការសិក្សាត្រៀមរបស់កូនលោកអ្នក មួយច្បាប់ដែលបានបំពេញហើយ។

សេចក្តីអធិប្បាយអំពីដំណាក់កាលឆ្លងកាត់របស់កូនលោកអ្នក មានផ្ទុកនូវព័ត៌ មានផ្ទាល់ខ្លួនមួយចំនួនអំពីកូនរបស់លោកអ្នក រួមមានឈ្មោះរបស់កូនលោកអ្នក ថ្ងៃខែឆ្នាំកំណើត និងរូបថតរបស់កូនលោកអ្នក ព្រមទាំងឈ្មោះ និងព័ត៌មាន ទំនាក់ទំនងលម្អិតរបស់លោកអ្នក។ នៅពេលមានការពាក់ព័ន្ធ វាក៏នឹងមានដាក់ ឈ្មោះ និងព័ត៌មានទំនាក់ទំនងលម្អិតអំពីអ្នកជំនាញផ្នែកអប់រំកុមារវ័យក្មេង ផ្សេងទៀតផងដែរ ដែលកំពុងជួយគាំទ្រកូនលោកអ្នក។

របាយការណ៍ស្តីអំពីការសិក្សាត្រៀម ជាទូទៅត្រូវបានសរសេរក្នុងឆមាសទី៤ ក៏ប៉ុន្តែប្រសិនបើកូនរបស់លោកអ្នកមានពិការភាព ឬភាពយឺតយ៉ាវនៃការរីក លូតលាស់ អ្នកអប់រំកុមារវ័យក្មេងរបស់កូនលោកអ្នកអាចសរសេរសេចក្តី អធិប្បាយអំពីដំណើរការឆ្លងកាត់ដំបូង ប្រហែលជានៅខែមិថុនា/កក្កដា ដើម្បីធ្វើជាកិច្ចពិភាក្សាដំបូងជាមួយលោកអ្នក និងសាលាដើម្បីកំណត់អំពី ការគាំទ្រនានាដែលកូនលោកអ្នកតម្រូវការ។

ដោយហេតុថា លោកអ្នកដឹងច្រើនអំពីកូនរបស់លោកអ្នក ការរួមចំណែករបស់ លោកអ្នកក្នុងរបាយការណ៍នេះមានគុណតម្លៃណាស់។

VICTORIA State Government | Education and Training

លោកអ្នកនឹងត្រូវបាន អញ្ជើញឱ្យបំពេញផ្នែកមួយនៃរបាយការណ៍ស្ដីអំពីការសិក្សាត្រៀម។ ការបំពេញ ផ្នែកនេះនៃរបាយការណ៍ស្ដីអំពីការសិក្សាត្រៀម នឹងជួយដល់សាលាចាប់យល់ ដឹងពីរបៀបដែលគេអាចជួយលោកអ្នក និងកូនរបស់លោកអ្នក ដូច្នេះហើយ លោកអ្នកទាំងពីរអាចចាប់ផ្ដើមជួយកូនលោកអ្នកចូលសាលាបានយ៉ាងល្អ ប្រសើរ។

ក៏មានផ្នែកសម្រាប់កូនរបស់លោកអ្នកបំពេញផងដែរ (ដោយមានជំនួយពី មនុស្សពេញវ័យ អាចជាលោកអ្នក ឬគ្រូអប់រំកុមារវ័យក្មេង)។ ផ្នែកនេះ ជាទូទៅ រួមបញ្ចូលទាំងគំនូរ និងការកត់ត្រាពីអ្វីដែលកូនរបស់លោកអ្នកចង់ដឹងអំពីសា លា និងពីអ្វីដែលពួកគេគិតអំពីការចាប់ផ្ដើមចូលសាលា។

## របៀបចែករំលែកព័ត៌មានជាមួយសាលារបស់កូនលោកអ្នក

ចាប់ពីឆ្នាំ២០១៧ របាយការណ៍ស្ដីអំពីការសិក្សាត្រៀម នឹងត្រូវបានបញ្ចប់ ចែករំលែក និងរក្សាទុកដោយប្រើប្រាស់នៅលើបណ្ដាញអនឡាញ ដែលបាន បង្ហោះលើ *Insight Assessment Platform (វេទិកាអនឡាញដែល មានឧបករណ៍/វិធីវាយតម្លៃ)*។ រាល់ព័ត៌មានទាំងអស់ដែលបានបង្ហោះលើ *Insight Assessment Platform* ត្រូវបានរក្សាទុកដោយសុវត្ថិភាពក្នុង ប្រទេសអូស្ត្រាលី។

*Insight Assessment Platform* ត្រូវបានដាក់ឱ្យប្រើប្រាស់រួចហើយនៅ តាមបណ្ដាសាលារដ្ឋវិចតូរីយ៉ាទាំងអស់។ វាបង្ហោះឯកសារវាយតម្លៃ ហើយ អនុញ្ញាតឱ្យសាលាបង្កើតឯកសារកំណត់ត្រាយូរអង្វែង អំពីការរៀនសូត្រ និងការរីកចម្រើនរបស់កូនលោកអ្នក។ បណ្ដាសាលាកាតូលិក និងសាលាឯក រាជ្យមួយចំនួន ក៏អាចទទួលបានរបាយការណ៍ស្ដីអំពីការសិក្សាត្រៀមរបស់កូន លោកអ្នកដែរ តាមរយៈ *Insight Assessment Platform* ឬ គេនឹងទទួល បានច្បាប់ចម្លងជាក្រដាស ឬអេឡិចត្រូនិក ពីសេវាអប់រំកុមារវ័យក្មេងរបស់កូន លោកអ្នក។

ក្រសួងអប់រំ និងបណ្ដុះបណ្ដាល(ក្រសួង) ប្រគល់មុខការក្រោមកិច្ចសន្យាមួយ ចំនួនរបស់ខ្លួនទៅអ្នកផ្ដល់សេវា ខាងក្រៅ។ ក្នុងករណីនេះកើតឡើង វិធានការ កិច្ចការពារសុវត្ថិភាពទិន្នន័យត្រូវបានតម្រូវដោយក្រសួង ដែលជា ផ្នែកមួយនៃដំណើរការក្រោមកិច្ចសន្យានេះ។ ក្រសួងបានធ្វើការវាយតម្លៃផលប៉ះពាល់ភាព ឯកជននៃ *Insight Assessment Platform* ដើម្បីធានាភាពអនុលោម តាម គោលនយោបាយព័ត៌មានភាពឯកជន និងច្បាប់ ភាពឯកជនដែលពាក់ព័ន្ធ របស់ក្រសួងនៅតាមវិបសាយ [www.education.vic.gov.au/Pages/privacypolicy](http://www.education.vic.gov.au/Pages/privacypolicy)។

ព័ត៌មានពីរបាយការណ៍ស្ដីអំពីការសិក្សាត្រៀម និងទិន្នន័យមួយចំនួនអំពី ការចុះឈ្មោះចូលរៀន អាចត្រូវបានប្រើប្រាស់ដោយក្រសួងក្នុងគោលបំណង តាមដាន និងស្រាវជ្រាវ។ ព័ត៌មាននេះត្រូវបានបង្ហាញជាទម្រង់ស្ថិតិ (ឧ. តួលេខ និងក្រាហ្វ) ហើយនឹង**មិន**ដាក់ឈ្មោះកុមារម្នាក់ៗទេ។

សម្រាប់ព័ត៌មានបន្ថែមអំពី *Insight Assessment Platform* សូមទាក់ទង ក្រសួងអប់រំ និងបណ្ដុះបណ្ដាលតាមរយៈអ៊ីម៉េល psts@edumail.vic.gov.a។

## សម្រាប់ព័ត៌មានបន្ថែម

សូមបើកចូលវិបសាយ [www.education.vic.gov.au/transitiontoschool](http://www.education.vic.gov.au/transitiontoschool)

ឯកសារនេះត្រូវបានបកប្រែចេញជាភាសាសហគមន៍មួយចំនួន ដែលអាចទទួលយកបានពីវិបសាយ [www.education.vic.gov.au/transitiontoschool](http://www.education.vic.gov.au/transitiontoschool)។